ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

លេខ ០៥៧ ព.ណ.កសប

ភ្នំពេញ, ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥

**<u>ជម្រាបមក</u>**

**លោកនាយកក្រុមហ៊ុន សេង ហុងហេង អាហ៌រណ នីហ៌រណ និងដឹកជញ្ជូន**

**កម្មវត្ថុៈ** ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកគ្រឿងម៉ាក NOR KOR TOR & DIAMOND DEVICE និង DIAMOND DEVICE ON THE TILE ក្នុងព្រះរាជាណាចក្រកម្ពុជាសាជាថ្មី របស់ក្រុមហ៊ុន **សេង ហុងហេង អាហ៌រណ នីហ៌រណ និងដឹកជញ្ជូន** ។

**យោងៈ**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **សេង ហុងហេង អាហ៌រណ នីហ៌រណ និងដឹកជញ្ជូន** ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន DIAMOND BUILDING PRODUCTS PUBLIC COMPANY LIMITED ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥
- លិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់ក្រសួងពាណិជ្ជកម្មលេខ ៤២០៦ ព.ណ កសប ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីម៉ាក NOR KOR TOR & DIAMOND DEVICE និង DIAMOND DEVICE ON THE TILE លេខចុះបញ្ជី KH/១៨១៤៦/០៣ និងលេខចុះបញ្ជី KH/១៨១៤៧/០៣ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១២ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយកថា ក្រសួងពាណិជ្ជកម្ម ឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកគ្រឿងម៉ាក NOR KOR TOR & DIAMOND DEVICE និង DIAMOND DEVICE ON THE TILE ក្នុងព្រះរាជាណាចក្រកម្ពុជាសាជាថ្មី របស់ក្រុមហ៊ុន **សេង ហុងហេង អាហ៌រណ នីហ៌រណ និងដឹកជញ្ជូន** ដែលទទួលបានពីក្រុមហ៊ុន DIAMOND BUILDING PRODUCTS PUBLIC COMPANY LIMITED ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ មានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ គិតចាប់ពីក្រោយថ្ងៃចុះហត្ថលេខាចំនួន ៩០(កៅសិប) ថ្ងៃ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន DIAMOND BUILDING PRODUCTS PUBLIC COMPANY LIMITED ដែលជាម្ចាស់ម៉ាក NOR KOR TOR & DIAMOND DEVICE និង DIAMOND DEVICE ON THE TILE នេះ។

នីតិបុគ្គលដែលទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៃផលិតផលម៉ាក NOR KOR TOR & DIAMOND DEVICE និង DIAMOND DEVICE ON THE TILE ត្រូវបោះពុម្ពផ្សាយលិខិតទទួលស្គាល់នេះក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានច្បាប់ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការគ្រប់គ្រងសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ។

អាស្រ័យហេតុនេះ សូមលោកនាយកក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ
អ៊ុក-ប្រេជា

<u>ចម្លងជូនៈ</u>
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*